ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៩. សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការចម្រុះដើម្បីរៀបចំបើកច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការចម្រុះដើម្បីរៀបចំបើកច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ ដែលមានសមាសភាពដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ស៊ុន ចាន់ថុល** | ទេសរដ្ឋមន្ត្រី និងជាអនុប្រធានប្រចាំការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រធាន |
| ២. ឯកឧត្តម | **ត្រាំ អ៊ីវតឹក** | រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣. ឯកឧត្តម | **គង់ វិបុល** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤. ឯកឧត្តម | **ឡុង វិសាលោ** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៥. ឯកឧត្តម | **សក់ សេដ្ឋា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៦. ឯកឧត្តម | **គីមរ៉េត សំរេច** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧. ឯកឧត្តម | **ឈួន ដារ៉ា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៨. ឯកឧត្តម | **ប៉ែន ស៊ីម៉ន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករ | សមាជិក |

| | | | |
|---|---|---|---|
| ៩. ឯកឧត្តម | **ហួន សាវ៉ាន** | អនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិ ទទួលបន្ទុកកិច្ចការព្រំដែន | សមាជិក |
| ១០. ឯកឧត្តម | **អ៊ុំ រឿន** | អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ | សមាជិក។ |

**ប្រការ ២ -**

គណៈកម្មការចម្រុះដើម្បីរៀបចំបើកច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ មានភារកិច្ចដូចខាងក្រោម ÷

- សហការ និងសម្របសម្រួលជាមួយភាគីថៃ ក្នុងដំណើរការរៀបចំបើកច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ ដែលមានទីតាំងស្ថិតនៅក្នុងភូមិស្ទឹងបត់ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដើម្បីសម្រួលដល់ដំណើរការដឹកទំនិញឆ្លងកាត់គ្រប់ប្រភេទ
- ពិនិត្យ និងកំណត់ចំណុចទីតាំងដែលត្រូវបើកច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ និងទីតាំងដែលត្រូវសាងសង់ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារ
- ធ្វើរបាយការណ៍ និងលើកយោបល់ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

**ប្រការ ៣.-**

សមាជិកគណៈកម្មការចម្រុះដើម្បីរៀបចំបើកច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និងអាចប្រើប្រាស់មន្ត្រីក្នុងអង្គភាពរបស់ខ្លួនបន្ថែមទៀតតាមសំណូមពរ និងទំហំការងារជាក់ស្តែង។

**ប្រការ ៤.-**

គណៈកម្មការចម្រុះដើម្បីរៀបចំបើកច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ មានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*